សហព័ន្ធ ស្រូវ អង្ករ កម្ពុជា
Cambodia Rice Federation

លេខ:០០២៣/១៥ ស.អ.ក

# ប្រកាស
## ស្ដីពី
## ការបង្កើតគណៈកម្មាធិការ ទទួលបន្ទុកលើការកែទម្រង់ថ្លៃដើម អង្ករកម្ពុជា
(Cost Competiveness Executive Committee)

## ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា

- បានឃើញអនុក្រឹត្យស្ដីពីការទទួលស្គាល់នៃការបង្កើតសហព័ន្ធស្រូវអង្ករកម្ពុជា លេខ ២២៨ អនក្រ.បក ចុះថ្ងៃទី ៨ សីហា ឆ្នាំ ២០១៤ ដោយនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញលក្ខន្តិកៈសហព័ន្ធស្រូវអង្ករកម្ពុជា អនុម័តដោយអង្គមហាសន្និបាតកាលពីថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ ២០១៥
- យោងតាមការចាំចាច់របស់សហព័ន្ធស្រូវអង្ករកម្ពុជា

## សម្រេច

**ប្រការ១.**

បង្កើតគណៈកម្មាធិការ ទទួលបន្ទុកលើការកែទម្រង់ឲ្យមានការប្រកួតប្រជែងថ្លៃដើម (Cost Competiveness Executive Committee) ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១.ឧកញ៉ា គឹម សាវុធ អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា | ប្រធាន |
| ២. លោក នង វាសនា នាយកក្រុមហ៊ុន NKL | អនុប្រធាន |
| ៣. លោក យន់ សុវណ្ណ ប្រធានក្រុមហ៊ុន Bayon Cereal | សមាជិក |
| ៤. លោក អ៊ិត វិជិត ទីប្រឹក្សាជាន់ខ្ពស់ របស់សហព័ន្ធស្រូវអង្ករកម្ពុជា | សមាជិក |
| ៥.លោក ងួន លី ក្រុមហ៊ុន Mekong Oryza | សមាជិក |
| ៦.លោក ស៊ឹម សុភា ក្រុមហ៊ុន Crystal Rice | សមាជិក |
| ៧. លោក យ៉ាន់ ពេជ្រ មន្ត្រីសហព័ន្ធស្រូវអង្ករកម្ពុជា | សមាជិក |
| ៨.លោក ពៅ បុណ្ណរិទ្ធ មន្ត្រីសហព័ន្ធស្រូវអង្ករកម្ពុជា | សមាជិក |
| ៩.តំណាង ក្រុមហ៊ុន ដឹកជញ្ជូន | សមាជិក |
| ១០.តំណាង ក្រុមហ៊ុន ជំរះឯកសារ (Frieght Fowarder) | សមាជិក |
| ១១. លោក ហ៊ីម ខទៀត មន្ត្រីសហព័ន្ធស្រូវអង្ករកម្ពុជា | លេខាធិការ |

**ប្រការ២.**

គណៈកម្មាធិការមានភារៈកិច្ចអនុវត្តការងារដោយស្ម័គ្រចិត្តលើកិច្ចការ នៅក្នុងក្របខ័ណ្ឌដែលមានចែងនៅក្នុងផែនការសកម្មភាព ដែលបានអនុម័តដោយ ក្រុមប្រឹក្សាភិបាលតាមការងារដូចខាងក្រោមៈ

- ជួសមុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាល ដើម្បីសិក្សាលើថ្លៃដើមនៃការដាំដុះ ការផលិត ការកិនកែច្នៃ ការវេចខ្ចប់ ការដឹកជញ្ជូន ការធ្វើការឯកសារនាំចេញរបស់អង្ករកម្ពុជា រួចស្នើរកដំណោះស្រាយរួមជាមួយរាជរដ្ឋាភិបាល សេវាករវិស័យឯកជន ក្នុងការជម្រុញឲ្យការកាត់បន្ថយថ្លៃដើមផលិតកម្ម ការកែច្នៃ និងការនាំចេញ ទៅកាន់ទីផ្សារអន្តរជាតិឲ្យកាន់តែមានភាពប្រកួតប្រជែងប្រសើរជាងមុន។
- ជួសមុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាល សហព័ន្ធ ក្នុងការចចារ ស្វែងរកដំណោះស្រាយ ជាមួយក្រសួងអាជ្ញាធរ អង្គភាពស្វយ័តនានារបស់រដ្ឋ និងបណ្តាលក្រុមហ៊ុនផ្តល់សេវានានា ដែលពាក់ព័ន្ធ ដល់ដំណើរការផលិតកម្ម ការកិនកែច្នៃ និងការនាំចេញអង្កររបស់កម្ពុជា។
- ជួសមុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាល សហព័ន្ធ ក្នុងការចរចារ ជាមួយក្រសួង ស្ថាប័នជាតិ អន្តរជាតិ ទីភ្នាក់ងារអភិវឌ្ឍន៍នានា ក្នុង ការស្វែងរកនូវ កិច្ចសហប្រតិបត្តិការ ការកៀងគរ រកនូវជំនួយសំរាប់ជួយដល់ការធ្វើសកម្មភាពការជម្រុញឲ្យមានការវិនិយោគ ជួយឧបត្ថម្ភដល់វិស័យស្រូវអង្ករកម្ពុជា ។
- គណៈកម្មាធិការត្រូវធ្វើរបាយការណ៍ ជាទៀងទាត់ជូនដល់ក្រុមប្រឹក្សាភិបាល សហព័ន្ធស្រូវអង្ករកម្ពុជា ។ ចំពោះករណី ការងារណាដែលមិនមានចែងក្នុង ក្របខ័ណ្ឌ ផែនការសកម្មភាព គណៈកម្មាធិការត្រូវស្នើសុំដល់ក្រុមប្រឹក្សាភិបាលអនុញ្ញាត្តិសំរេចជាមុន។
- ក្នុងករណីចំបាច់ គណៈកម្មាធិការអាចស្នើសុំបន្ថែមសមាជិក និង ទីប្រឹក្សាសំរាប់គណៈកម្មាធិការនេះ។

**ប្រការ៣.**

ក្រុមប្រឹក្សាភិបាល លេខាធិការដ្ឋាន ការិយាល័យសាខាតាមខេត្ត និង សាម៉ីខ្លួន ត្រូវអនុត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានី ភ្នំពេញ ថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០១៥

**ប្រធាន**

CAMBODIA RICE FEDERATION

**សុខ ពុទ្ធិវុធ**

<u>ចំលងជូន</u>

- ខុទ្ទកាល័យ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យ រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ខុទ្ទកាល័យ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ខុទ្ទកាល័យ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ រដ្ឋមន្ត្រីក្រសួងថាមពល និង រ៉ែ
- ការិយាល័យច្រកចេញចូលតែមួយ
- គំរោងពាណិជ្ជកម្មស្រូវនៅកម្ពុជា របស់ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ដូចប្រការ ៣
- ឯកសារ កាលប្បវត្តិ